ក្រសួងសុខាភិបាល

# និយាមបែបបទសំរាប់ធ្វើតេស្តស្រាវជ្រាវ
# រកមេរោគស្វាយចំពោះស្ត្រីមានផ្ទៃពោះ
# នៅព្រះរាជាណាចក្រកម្ពុជា

ឆ្នាំ ២០០៨

**មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ**

**មជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក**

ថ្ងៃទី ០៣ ខែវិច្ឆិកា ឆ្នាំ ២០០៨

# គោរពជូន

# ឯកឧត្តមសាស្ត្រាចារ្យ អេង ហួត

# រដ្ឋលេខាធិការក្រសួងសុខាភិបាល

សូមគោរពជូនឯកឧត្តមសាស្ត្រាចារ្យមេត្តាជ្រាបថា មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ និង មជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក បានសហការយ៉ាងជិតស្និទ្ធជាមួយនឹងដៃគូអភិវឌ្ឍន៍សុខាភិបាល ជាពិសេសអង្គការមិនមែនរដ្ឋាភិបាល រៀបចំ សេចក្តីព្រាងនៃនិយាមបែបបទសំរាប់ធ្វើតេស្តស្រាវជ្រាវរកមេរោគស្វាយចំពោះស្ត្រីមានផ្ទៃពោះនៅព្រះរាជាណាចក្រកម្ពុជា ដើម្បីប្រើប្រាស់ជាគោលការណ៍រួមនៃមជ្ឈមណ្ឌលជាតិទាំងពីរ សំរាប់អនុវត្តយុទ្ធសាស្ត្រជាតិសុខភាពបន្តពូជ និងសុខភាពផ្លូវភេទ ក្នុងការទប់ស្កាត់ការចំលងមេរោគស្វាយពីម្តាយទៅកូនប្រកបដោយប្រសិទ្ធិភាពខ្ពស់ ឈានទៅលុបបំបាត់ជំងឺស្វាយពីកំណើត ចំពោះទារកនៅក្នុងព្រះរាជាណាចក្រកម្ពុជានាពេលអនាគត ។

សូមឯកឧត្តមរដ្ឋលេខាធិការមេត្តាពិនិត្យ និងសំរេចដោយក្តីអនុគ្រោះ ។

សូមឯកឧត្តមរដ្ឋលេខាធិការមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ ។

**វេជ្ជ. មាន ឈីវុន**

ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ

**សាស្ត្រាចារ្យ គុំ កាណាល់**

ប្រធានមជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក

# អារម្ភកថា

ក្រសួងសុខាភិបាលបានទទួលស្គាល់ថា ការបង្ការការចំលងមេរោគស្វាយពីម្តាយទៅកូនគឺជាអាទិភាពមួយក្នុងចំណោមអាទិភាពនានានៃយុទ្ធសាស្ត្រជាតិសុខភាពបន្តពូជនិងសុខភាពផ្លូវភេទនៅប្រទេសកម្ពុជានៅឆ្នាំ ២០០៦-២០១០។ ការអនុវត្តន៍យុទ្ធសាស្ត្រជាតិនេះ ត្រូវមានគោលការណ៍ និងយន្តការច្បាស់លាស់មួយជាស្តង់ដារ ដើម្បីអោយសេវាថែទាំសុខភាពនានារបស់រដ្ឋ ក៏ដូចជាគ្លីនិកសុខភាពរបស់អង្គការមិនមែនរដ្ឋាភិបាលអនុវត្តប្រកបដោយប្រសិទ្ធិភាពខ្ពស់សមស្របទៅនឹងស្ថានភាពបច្ចុប្បន្ននៃសេវាសុខភាពដែលមានស្រាប់និងកំពុងដំណើរការនៅក្នុងប្រទេសកម្ពុជា។

ក្រសួងសុខាភិបាល ជឿជាក់ថា **និយាមបែបបទសំរាប់ធ្វើតេស្តស្រាវជ្រាវរកមេរោគស្វាយចំពោះស្ត្រីមានផ្ទៃពោះនៅកម្ពុជា** នេះគឺជាឯកសារដ៏សំខាន់មួយទៀត សំរាប់មន្ត្រីសុខាភិបាលដែលកំពុងបំរើការងារនៅតាមសេវាថែទាំសុខភាពបន្តពូជនិងសុខភាពផ្លូវភេទ ជាពិសេសសេវាថែទាំផ្ទៃពោះមុនពេលសំរាលនៅតាមមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក ព្រមទាំងគ្លីនិកសុខភាពបន្តពូជនៃអង្គការមិនមែនរដ្ឋាភិបាល ប្រើប្រាស់ជាមូលដ្ឋានគ្រឹះនៃការចូលរួមចំណែកទប់ស្កាត់ការចំលងមេរោគស្វាយពីម្តាយទៅកូន ដើម្បីឈានទៅលុបបំបាត់ជំងឺស្វាយពីកំណើតចំពោះទារកនៅក្នុងព្រះរាជាណាចក្រកម្ពុជានាពេលអនាគត។

ក្នុងឱកាសនេះ ខ្ញុំសូមថ្លែងនូវការកោតសសើរដល់មជ្ឈមណ្ឌលជាតិទាំងពីរ ព្រមទាំងដៃគូអភិវឌ្ឍន៍សុខាភិបាលទាំងអស់ដែលបានខិតខំប្រឹងប្រែងសហការរៀបចំអោយមានជានិយាមបែបបទសំរាប់អនុវត្តការធ្វើតេស្តស្រាវជ្រាវរកមេរោគស្វាយចំពោះស្ត្រីមានផ្ទៃពោះនៅប្រទេសកម្ពុជា។

ភ្នំពេញ, ថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ២០០៨

**សាស្ត្រាចារ្យ អេង ហួត**

**រដ្ឋលេខាធិការក្រសួងសុខាភិបាល**

# សេចក្តីថ្លែងអំណរគុណ

មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ និង មជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះលោក-លោកស្រីទាំងអស់ដែលជា សមាជិក-សមាជិកានៃក្រុមការងារបច្ចេកទេសសំរាប់ការបង្ការ និងថែទាំព្យាបាលការបង្ករោគតាមការរួមភេទ និងប្រដាប់បន្តពូជ ដែលបានអញ្ជើញមកពីមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ, មជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក, វិទ្យាស្ថានជាតិសុខភាពសាធារណៈ, គ្លីនិកសុខភាពសង្គម, អង្គការ RHAC, RACHA, FHI, PSF, PSI, MEC, Marie Stopes, US-CDC, UNFPA, WHO, CHAI, UNICEF និងវិទ្យាស្ថាន ITM ដែលបានចូលរួមចំណែករៀបចំនិយាមបែបបទសំរាប់ធ្វើតេស្តស្រាវជ្រាវរកមេរោគស្វាយចំពោះស្ត្រីមានផ្ទៃពោះនៅកម្ពុជា ។

និយាមបែបបទនេះ គឺជាឯកសារស្តង់ដារដែលមានសារៈសំខាន់សំរាប់អនុវត្តវិធីសាស្ត្រខាងលើនេះប្រកបដោយគុណភាព និងប្រសិទ្ធិភាពខ្ពស់ ។

ភ្នំពេញ, ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ ២០០៨

វេជ្ជ. មាន ឈីវុន

ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍

សើស្បែក និងកាមរោគ

## ១ សេចក្តីផ្តើម

ទោះបីជាសព្វថ្ងៃនេះ មានបច្ចេកវិទ្យាវេជ្ជសាស្រ្តយ៉ាងទូលំទូលាយសំរាប់ការធ្វើរោគវិនិច្ឆ័យ និងព្យាបាលការបង្ករោគស្វាយចំពោះស្រ្តីមានផ្ទៃពោះក៏ដោយ ជំងឺស្វាយនៅតែជាបញ្ហាចំបងនៃសុខភាពសាធារណៈ ជាពិសេសផលវិបាកដល់ទារកពេលមុន និងក្រោយកំណើត នៅប្រទេសជាច្រើនលើពិភពលោក។ គេបានប៉ាន់ស្មានថា ២ភាគ៣នៃស្រ្តីមានផ្ទៃពោះដែលមានជំងឺស្វាយដំណាក់កាលដំបូងហើយមិនបានទទួលការព្យាបាល អាចនឹងវិវត្តទៅរកការរលូតកូន, កូនកើតមកស្លាប់ ឬក៏ការបង្ករោគចំពោះកូនដែលទើបនឹងកើត។

តាមការអង្កេតស្រាវជ្រាវអត្រាប្រេវ៉ាឡង់នៃការឆ្លងមេរោគស្វាយ (ដោយធ្វើតេស្ត RPR និងបញ្ជាក់លទ្ធផលដោយតេស្ត TPHA) ចំពោះស្រ្តីមានផ្ទៃពោះដែលបានមកពិនិត្យសុខភាពនៅសេវាពិនិត្យផ្ទៃពោះ បានបង្ហាញថា ស្រ្តីមានផ្ទៃពោះ ៤.0% នៅឆ្នាំ ១៩៩៦ និង 0.៧% នៅឆ្នាំ ២00១ មានមេរោគស្វាយ។ ក៏ប៉ុន្តែរហូតមកដល់បច្ចុប្បន្ននេះ ពុំទាន់មានរបាយការណ៍ណាមួយស្តីពីករណីជំងឺស្វាយពីកំណើតចំពោះទារក នៅក្នុងប្រព័ន្ធពត៌មាននៃក្រសួងសុខាភិបាលនៅឡើយទេ។ មូលហេតុនេះបណ្តាលអោយមានការលំបាកក្នុងការកំណត់អោយបានច្បាស់ថា តើជំងឺស្វាយពីកំណើតនៅប្រទេសកម្ពុជា ជាបញ្ហាធ្ងន់ធ្ងរប៉ះពាល់ដល់សុខភាពទារកកំរិតណា?។ ទោះបីជាជំងឺស្វាយ ជាជំងឺដែលបង្កផលវិបាកយ៉ាងធ្ងន់ធ្ងរដល់ស្រ្តីមានផ្ទៃពោះ និងទារកដែលទើបនឹងកើតក៏ដោយ ក៏ជំងឺនេះងាយស្រួលនឹងបង្ការណាស់ តាមវិធីសាស្រ្តគ្រប់គ្រងថែទាំព្យាបាលជំងឺកាមរោគដែលអាចអនុវត្តបាននៅប្រទេសកម្ពុជា។

គោលនយោបាយ និងយុទ្ធសាស្រ្តជាតិស្តីពីការបង្ការ និងថែទាំព្យាបាលការបង្ករោគតាមការរួមភេទ ឆ្នាំ ២00៦-២0១0 (គោលនយោបាយទី ៨) បានបញ្ចូលនូវយុទ្ធសាស្រ្តនៃការយកចិត្តទុកដាក់ជាពិសេសរបស់ក្រសួងសុខាភិបាល ចំពោះសុខភាពស្រ្តីមានផ្ទៃពោះនិងទារកទើបនឹងកើតដែលអាចប្រឈមមុខនឹងការបង្ករោគតាមការរួមភេទនិងប្រដាប់បន្តពូជ។

យុទ្ធសាស្រ្តជាតិស្តីពីសុខភាពផ្លូវភេទនិងសុខភាពបន្តពូជ, ឆ្នាំ២00៦-២0១0 ក៏បានកំណត់ថា ជំងឺនៅប្រដាប់បន្តពូជ (រួមទាំងជំងឺកាមរោគ) គឺជាផ្នែកដ៏សំខាន់មួយនៃកម្មវិធីសុខភាពបន្តពូជនៅប្រទេសកម្ពុជាយើង។

## ២ គោលបំណងរួម

គោលបំណងរួមនៃការធ្វើតេស្តស្រាវជ្រាវរកមេរោគស្វាយចំពោះស្រ្តីមានផ្ទៃពោះគឺ ដើម្បីកំចាត់ជំងឺស្វាយពីកំណើតចំពោះទារកដែលទើបនឹងកើតទាំងអស់នៅប្រទេសកម្ពុជា។

## ៣ ទិសដៅសំខាន់ៗ

ទិសដៅសំខាន់គឺ ការបង្ការការចំលងមេរោគស្វាយពីម្តាយទៅកូន ដោយផ្តោតទៅលើទិសដៅពិសេសមួយចំនួន ដូចខាងក្រោមនេះ :

៣.១ កំណត់រោគវិនិច្ឆ័យនៃតេស្តសេរ៉ូសាស្ត្រ វិជ្ជមាន ចំពោះស្ត្រីមានផ្ទៃពោះ

៣.២ ព្យាបាលស្ត្រីមានផ្ទៃពោះ ( ម្តាយ) និងដៃគូ ដើម្បីកាត់បន្ថយការចំលងរោគ

៣.៣ ព្យាបាលនិងតាមដានសុខភាពទារក

និយាមបែបបទសំរាប់ការអនុវត្តន៍នេះ ក៏មានបញ្ចូលផងដែរនូវការពិនិត្យតាមដានអំពីប្រសិទ្ធិភាពនៃការថែទាំព្យាបាលចំពោះម្តាយផងដែរ ។

## ៤ យុទ្ធសាស្ត្រ

### ៤.១ កំណត់រោគវិនិច្ឆ័យនៃតេស្តសេរ៉ូសាស្ត្រវិជ្ជមានចំពោះស្ត្រីមានផ្ទៃពោះ

- អ្នកផ្តល់សេវាថែទាំសុខភាពនៅផ្នែកពិនិត្យផ្ទៃពោះមុនពេលសំរាលនៃមណ្ឌលសុខភាព, មន្ទីរពេទ្យបង្អែក និងគ្លីនិកអង្គការមិនមែនរដ្ឋាភិបាលទាំងអស់ ត្រូវជំរុញលើកទឹកចិត្តដល់ស្ត្រីអោយធ្វើតេស្តស្រាវជ្រាវរកមេរោគស្វាយ បានយ៉ាងតិចណាស់ក៏មួយដងដែរ ក្នុងពេលមានផ្ទៃពោះ ។ ស្ត្រីមានផ្ទៃពោះទាំងអស់ ត្រូវធ្វើតេស្តស្រាវជ្រាវរកមេរោគស្វាយនៅពេលមកពិនិត្យលើកដំបូង ឬអោយបានកាន់តែឆាប់ក្នុងពេលមានផ្ទៃពោះ ប្រសិនបើអាចធ្វើទៅបាន ។ ប្រសិនបើស្ត្រីនោះមិនបានធ្វើតេស្ត ក្នុងពេលមានផ្ទៃពោះទេ គាត់ត្រូវធ្វើតេស្តនេះ នៅពេលសំរាលកូន ។
- តេស្តរហ័ស (Rapid test) “Bioline” សំរាប់ស្រាវជ្រាវរកមេរោគស្វាយ (Treponema-specific rapid diagnosis test) ត្រូវបានកំណត់អោយប្រើសំរាប់ធ្វើតេស្តស្រាវជ្រាវរកមេរោគស្វាយ ចំពោះស្ត្រីដែលមានផ្ទៃពោះ ជាពិសេសនៅពេលដែលគាត់មកពិនិត្យសុខភាពនៅផ្នែកពិនិត្យផ្ទៃពោះ ពីព្រោះអ្នកផ្តល់សេវាអាចប្រើតេស្តនេះបានរហ័ស និង ងាយស្រួលជាងតេស្តប្រភេទដទៃទៀត ។
- ទោះបីយ៉ាងណាក៏ដោយ Rapid test នេះមិនអាចកំណត់បានថា ជំងឺស្វាយនោះទើបតែឆ្លងថ្មី ឬឆ្លងយូរណាស់មកហើយ ឬក៏ជាជំងឺស្វាយដែលបានទទួលការព្យាបាល ឬមិនទាន់ព្យាបាលទេ ។ ដូច្នេះគេត្រូវយកសេរ៉ូមឈាមអ្នកជំងឺដែលមានលទ្ធផល Rapid test វិជ្ជមាននោះ បញ្ជូនទៅកាន់មន្ទីរពិសោធន៍ ដើម្បីធ្វើតេស្ត RPR បែបគុណភាព (qualitative test) បញ្ជាក់លើលទ្ធផល Rapid test បន្ថែមទៀត ។ លទ្ធផលតេស្ត RPR នេះអាច

បញ្ជាក់ថា ជំងឺស្វាយនោះជាជំងឺដែលទើបឆ្លងថ្មីៗ និងមិនទាន់ទទួលការព្យាបាលនៅឡើយ ដូច្នេះត្រូវផ្តល់ការព្យាបាលជូនអ្នកជំងឺនោះ ។

- ត្រូវអប់រំណែនាំដល់ស្ត្រីទាំងអស់ដែលមានលទ្ធផលតេស្តជំងឺស្វាយវិជ្ជមាន ដោយតេស្តប្រភេទណាក៏ដោយ អោយទៅមណ្ឌលផ្តល់ប្រឹក្សាធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់ ឬបូមឈាមគាត់ដែលបានស្ម័គ្រចិត្តធ្វើតេស្តឈាមរកមេរោគអេដស៍ ហើយបញ្ជូនសំណាកឈាមទៅសេវាធ្វើតេស្ត HIV ។

## ៤.១.១ ជំហាននានាសំរាប់ការធ្វើតេស្តស្រាវជ្រាវរកមេរោគស្វាយចំពោះស្ត្រីមានផ្ទៃពោះ នៅសេវាពិនិត្យផ្ទៃពោះ

### ៤.១.១.១ ជំហានទី ១:

- ស្ត្រីមានផ្ទៃពោះមកទទួលសេវាពិនិត្យផ្ទៃពោះជាលើកដំបូង
- ផ្តល់ពត៌មានស្តីពីសារៈប្រយោជន៍នៃការធ្វើតេស្តស្រាវជ្រាវរកមេរោគស្វាយចំពោះស្ត្រីមានផ្ទៃពោះ
- ពិនិត្យរកមើលដំបៅឬពងបែកលើប្រដាប់បន្តពូជ :
    - ប្រសិនបើមានដំបៅ ឬពងបែកលើប្រដាប់បន្តពូជ ត្រូវធ្វើរោគវិនិច្ឆ័យនិងព្យាបាលអ្នកជំងឺទៅតាមគំនូសបំព្រួញនៃគោលការណ៍ណែនាំជាតិ (សូមមើលឧបសម្ព័ន្ធទី ៩ និង គោលការណ៍ណែនាំជាតិស្តីពីការគ្រប់គ្រងថែទាំព្យាបាលការបង្ករោគតាមការរួមភេទ និងប្រដាប់បន្តពូជ)
    - ប្រសិនបើគ្មានដំបៅ ឬពងបែកលើប្រដាប់បន្តពូជទេ ត្រូវបន្តទៅជំហ៊ានទី២ ដើម្បីស្រាវជ្រាវរកមេរោគស្វាយដោយ Rapid test ។

### ៤.១.១.២ ជំហានទី ២:

- ដោះយកឈាមពីចុងម្រាមដៃ
- ធ្វើតេស្តរកមេរោគស្វាយដោយប្រើតេស្ត Treponema-specific rapid diagnosis test (RDT) “Bioline” (សូមមើលឧបសម្ព័ន្ធទី៣):
    - ប្រសិនបើលទ្ធផលតេស្ត អវិជ្ជមាន នោះបញ្ជាក់ថាស្ត្រីនោះគ្មានឆ្លងមេរោគស្វាយទេ។ ដូច្នេះត្រូវអប់រំ និងផ្តល់ប្រឹក្សាដល់គាត់ ជាពិសេសការអប់រំអំពីការប្រើប្រាស់និងផ្តល់ស្រោមអនាម័យដើម្បីជាមធ្យោបាយរួមសំរាប់បង្ការការឆ្លងមេរោគអេដស៍/កាមរោគ

និងការមានផ្ទៃពោះ។ ជាទីបញ្ចប់ ត្រូវផ្តល់ពត៌មានអំពីការផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមរកមេរោគអេដស៍។

- ប្រសិនបើលទ្ធផលតេស្ត វិជ្ជមាន ត្រូវបន្តទៅជំហ៊ានទី៣ ដើម្បីធ្វើតេស្ត RPR (qualitative) សំរាប់បញ្ជាក់អោយដឹងថា ជាជំងឺស្វាយដែលទើបនឹងឆ្លងថ្មីៗ។

- កំណត់ចំណាំ : លទ្ធផលនៃ Rapid test ត្រូវកត់ត្រាទុកនៅក្នុងបញ្ជីពិនិត្យផ្ទៃពោះ (Antenatal register) (សូមមើលឧបសម្ព័ន្ធទី៤)

**៤.១.១.៣ ជំហានទី ៣:**

- បូមឈាមចំនួន ៥ ម.ល. ដាក់ទៅក្នុងបំពង់ទីប (ដែលស្ងួតនិងបានសំលាប់មេរោគ) បន្ទាប់មកយកគំរបមកគ្របអោយជិត ហើយបញ្ជូនទៅមន្ទីរពិសោធន៍ដើម្បីធ្វើតេស្ត RPR (qualitative)។ លទ្ធផលតេស្តត្រូវផ្តល់ជូនអ្នកជំងឺអោយបានឆាប់។
    - ប្រសិនបើលទ្ធផលតេស្ត អវិជ្ជមាន នោះអាចបញ្ជាក់បានថា ជំងឺស្វាយដែលបានរកឃើញ គឺជាជំងឺស្វាយដែលកើតមានពីមុនមកនិងបានទទួលការព្យាបាលរួចហើយ។ ត្រូវអប់រំ និងផ្តល់ប្រឹក្សាដល់គាត់ ជាពិសេសការអប់រំអំពីការប្រើប្រាស់និងផ្តល់ស្រោមអនាម័យដើម្បីជាមធ្យោបាយរួមសំរាប់បង្ការការឆ្លងមេរោគអេដស៍/កាមរោគ និងការមានផ្ទៃពោះ។ ជាទីបញ្ចប់ ត្រូវផ្តល់ពត៌មានអំពីការផ្តល់ប្រឹក្សានិងធ្វើតេស្តឈាម រកមេរោគអេដស៍។
    - ប្រសិនបើលទ្ធផលតេស្ត វិជ្ជមាន បញ្ជាក់ថាជំងឺស្វាយនោះទើបតែឆ្លងថ្មីៗ ហើយអាចមិនទាន់បានទទួលការព្យាបាលនៅឡើយ។ ដូច្នេះត្រូវ :
        - **ព្យាបាលជំងឺស្វាយ** (សូមមើលឧបសម្ព័ន្ធទី១) ជូនអ្នកជំងឺ និងអប់រំ - ផ្តល់ប្រឹក្សាដល់គាត់ ជាពិសេសការអប់រំអំពីការប្រើប្រាស់និងផ្តល់ស្រោមអនាម័យដើម្បី ជាមធ្យោបាយរួមសំរាប់បង្ការការឆ្លងមេរោគអេដស៍/កាមរោគ និងការមានផ្ទៃពោះ។ ជាទីបញ្ចប់ ត្រូវផ្តល់ពត៌មានអំពីការផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមរកមេរោគអេដស៍។

- កំណត់ចំណាំ : លទ្ធផលនៃតេស្ត RPR (qualitative) ត្រូវកត់ត្រាទុកនៅក្នុងបញ្ជីពិនិត្យផ្ទៃពោះ (Antenatal register) (សូមមើលឧបសម្ព័ន្ធទី៤) ។

#### ៤.១.២ ការធ្វើតេស្តស្រាវជ្រាវរកមេរោគស្វាយចំពោះស្ត្រីមានផ្ទៃពោះ នៅសេវាសំរាលកូន

- ស្ត្រីមានផ្ទៃពោះទាំងអស់ត្រូវធ្វើតេស្តស្រាវជ្រាវរកជំងឺស្វាយនៅសេវាសំរាលកូន ប្រសិនបើស្ត្រីនោះមិនទាន់បានធ្វើតេស្តនេះក្នុងកំលុងពេលមានផ្ទៃពោះ ហើយគាត់មិនទាន់ឈឺពោះសំរាលកូននៅឡើយ ។
- ដំណើរការនៃការធ្វើតេស្តស្រាវជ្រាវ និងព្យាបាលជំងឺស្វាយនៅសេវាសំរាលកូន គឺដូចគ្នានឹងដំណើរការនៅសេវាពិនិត្យផ្ទៃពោះមុនពេលសំរាលដែរ ។

## ៤.២ ការគ្រប់គ្រងព្យាបាលម្តាយ និងដៃគូរួមភេទរបស់គាត់ដើម្បីកាត់បន្ថយការចំលងមេរោគស្វាយ

### ៤.២.១ ការព្យាបាលចំពោះម្តាយ

#### ៤.២.១.១ ពេលវេលានៃការព្យាបាល :

- ត្រូវព្យាបាលម្តាយភ្លាមៗ បន្ទាប់ពីការបញ្ជាក់ដោយតេស្ត RPR (qualitative) បង្ហាញលទ្ធផល វិជ្ជមាន ជាពិសេសការព្យាបាលនេះ គប្បីផ្តល់ដោយមន្ត្រីសុខាភិបាលនៅផ្នែកពិនិត្យផ្ទៃពោះមុនពេលសំរាល (ANC service) ។
- ត្រូវសាកសួរអ្នកជំងឺអំពីប្រវត្តិប្រតិកម្មជាមួយឱសថ មុននឹងផ្តល់ការព្យាបាលជូនគាត់ (សូមមើលឧបសម្ព័ន្ធទី៨)

#### ៤.២.១.២ ឱសថសំរាប់ព្យាបាល :

- ត្រូវប្រើឱសថ Benzathine Penicillin G 2.4 million unit ចាក់សាច់ដុំតែម្តងគត់ ចំពោះស្ត្រីមានផ្ទៃពោះទាំងអស់ដែលគ្មានរោគសញ្ញាប៉ុន្តែមានលទ្ធផលតេស្ត RPR វិជ្ជមាន។ ចំពោះស្ត្រីដែលមានជំងឺស្វាយដំណាក់កាលដំបូង (មានដំបៅលើប្រដាប់បន្តពូជ) និងជំងឺស្វាយដំណាក់កាលទីពីរ ត្រូវព្យាបាលតាមរូបមន្តដូចគ្នានេះដែរនេះ ។

<u>ករណីប្រតិកម្មជាមួយពពួកឱសថ Penicillin</u> :

- ត្រូវប្រើឱសថ Erythromycin 500mg លេប បួនដងក្នុង១ថ្ងៃ រយៈពេល ១៤ ថ្ងៃ ។

កំណត់ចំណាំ :

- ចំពោះស្ត្រីដែលផ្ទុកមេរោគអេដស៍ : គ្រូពេទ្យជំនាញខ្លះបានផ្តល់អនុសាសន៍អោយប្រើឱសថ Benzathine-Penicillin G 2.4 million units ចាក់សាច់ដុំ មួយដងក្នុងមួយសប្តាហ៍ រយៈពេលបីសប្តាហ៍បន្តបន្ទាប់គ្នា ដោយមានការពិនិត្យតាមដានអោយបានហ្មត់ចត់នៅសេវាថែទាំព្យាបាលជំងឺអេដស៍ ។ ដូច្នេះ វាមានសារៈសំខាន់ណាស់ដែលត្រូវបញ្ជូនស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍ ទៅទទួលការថែទាំព្យាបាលនៅសេវាថែទាំព្យាបាលជំងឺអេដស៍ ហើយត្រូវជូនពត៌មានអំពីលទ្ធផលតេស្តស៊េរ៉ូសាស្ត្រជំងឺស្វាយ វិជ្ជមាន ដល់អ្នកផ្តល់សេវានៅទីនោះផង ។

## ៤.២.២ ការអញ្ជើញដៃគូអោយមកព្យាបាល

- ត្រូវពិនិត្យតាមដាននិងអញ្ជើញដៃគូរួមភេទរបស់ស្ត្រីមានផ្ទៃពោះហើយឆ្លងមេរោគស្វាយអោយមកទទួលការថែទាំព្យាបាល
- ត្រូវព្យាបាលជំងឺស្វាយជូនដល់ដៃគូរួមភេទទាំងអស់នោះ នៅពេលដំណាលគ្នាជាមួយស្ត្រីមានផ្ទៃពោះតែម្តង ប្រសិនបើអាចធ្វើទៅបាន ដោយប្រើឱសថ Benzathine-Penicillin G 2.4 million units ចាក់សាច់ដុំ តែម្តងគត់ ។ ក្នុងករណីដែលអ្នកជំងឺនោះប្រតិកម្មជាមួយពពួក Penicillin ត្រូវប្រើឱសថ Erythromycin 500mg លេបបួនដងក្នុងមួយថ្ងៃ រយៈពេល ១៤ថ្ងៃ ឬ ឱសថ Doxycycline 100mg លេបពីរដងក្នុងមួយថ្ងៃ រយៈពេល ១៤ថ្ងៃ ។
- ត្រូវអប់រំដល់ដៃគូរួមភេទរបស់ស្ត្រីដែលមានលទ្ធផលតេស្តស្វាយវិជ្ជមាន អោយទៅទទួលសេវានៅមណ្ឌលផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់ (VCCT) ។

## ៤.២.៣ ការពិនិត្យតាមដានចំពោះម្តាយ

### ៤.២.៣.១ ក្រោយពីលទ្ធផល Rapid test និងតេស្ត RPR qualitative វិជ្ជមាន :

- ក្រោយពីលទ្ធផលតេស្ត RPR qualitative វិជ្ជមាន ត្រូវយកគំរូឈាមដដែលនោះទៅធ្វើតេស្ត RPR quantitative (RPR titre) ។ បន្ទាប់មក ត្រូវកត់ត្រាលទ្ធផលតេស្ត RPR titre នៅក្នុងសៀវភៅបញ្ជីពិនិត្យផ្ទៃពោះមុនពេលសំរាល “ Antenatal record ” (សូមមើលឧបសម្ព័ន្ធទី៥) និងសៀវភៅសុខភាពមាតា “ Mother Health’s Record book ” (សូមមើលឧបសម្ព័ន្ធទី៦) ដើម្បីរក្សាលទ្ធផលតេស្ត RPR titre នោះជាគោល (baseline)

សំរាប់ប្រៀបធៀបលទ្ធផលពិនិត្យតាមដានប្រសិទ្ធិភាពនៃការព្យាបាល នៅពេលដែលស្ត្រីជាម្តាយមកពិនិត្យសុខភាពលើកក្រោយៗទៀត។

**៤.២.៣.២ ក្រោយពីម្តាយបានទទួលការព្យាបាលជំងឺស្វាយ (សូមមើលឧបសម្ព័ន្ធទី២) :**

- ត្រូវប្រាប់អោយស្ត្រីដែលមានតេស្តជំងឺស្វាយ វិជ្ជមាន នោះ ត្រឡប់មកជួបអ្នកវិញ រយៈពេលពី ៦ ទៅ ១២ខែ ក្រោយពីគាត់បានទទួលការព្យាបាល ដើម្បីពិនិត្យតាមដានប្រសិទ្ធិភាពនៃការព្យាបាល ដោយការធ្វើតេស្ត RPR quantitative (RPR titre) សារឡើងវិញ។ ជាការប្រសើរ ម្តាយគប្បីត្រឡប់មកពិនិត្យតាមដានឡើងវិញនៅខែទី៩ ពេលដែលគាត់យកកូនមកចាក់ថ្នាំបង្ការជំងឺកញ្ជ្រិល។
- គប្បីធ្វើតេស្ត RPR quantitative (RPR titre) នៅមន្ទីរពិសោធន៍ដដែល (មន្ទីរពិសោធន៍ដែលម្តាយបានធ្វើតេស្តនេះពីលើកមុន)។ ប្រសិនបើមានការប្រែប្រួលលទ្ធផល titre ៤ដងនៅចន្លោះល្បាយតេស្តពីរ (two dilutions) (ឧ. ពី ១:១៦ ទៅ ១:៤ ឬ ពី ១:៨ ទៅ ១:៣២) នោះអាចបញ្ជាក់ច្បាស់ថា មានការប្រែប្រួលលទ្ធផលរវាងតេស្តពីរ ដែលរកមេរោគស្វាយ ដោយប្រើប្រាស់ប្រភេទតេស្តតែមួយប្រភេទដូចគ្នា :
    - ប្រសិនបើលទ្ធផល RPR titre ថយចុះ ២ដងឬលើសពី២ដង (ឧ. ពី ១:១៦ ទៅ ១:៤) ឬ លទ្ធផលតេស្ត RPR qualitative អវិជ្ជមាន ត្រូវអប់រំនិងផ្តល់ប្រឹក្សាដល់គាត់ ជាពិសេសការអប់រំអំពីការប្រើប្រាស់ និងផ្តល់ស្រោមអនាម័យដើម្បីជាមធ្យោបាយរួមសំរាប់បង្ការការឆ្លងមេរោគអេដស៍/កាមរោគ និងការមានផ្ទៃពោះ ហើយត្រូវអញ្ជើញដៃគូរបស់គាត់អោយមកទទួលការព្យាបាល ប្រសិនបើដៃគូនោះមិនទាន់បានទទួលការព្យាបាលនៅឡើយ និងផ្តល់ពតិមានដល់គាត់និងដៃគូរបស់គាត់អំពីការផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមរកមេរោគអេដស៍ ប្រសិនបើគាត់ទាំងពីរនាក់មិនបានធ្វើតេស្តនេះកាលពីពេលមកពិនិត្យផ្ទៃពោះមុនពេលសំរាល ឬប្រសិនបើគាត់មានការប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ បើទោះបីជាលទ្ធផលតេស្តដែលបានធ្វើពីលើកមុនៗអវិជ្ជមានក៏ដោយ។

- ប្រសិនបើលទ្ធផល RPR titre គ្មានការថយចុះ៤ដងទេ ក្រោយពីការព្យាបាលជំងឺស្វាយអស់រយៈពេល៦ខែមក (ឧ. ប្រៀបធៀបជាមួយនឹងលទ្ធផល RPR titre ដែលបានធ្វើកាលពីលើកដំបូងនៅពេលចាប់ផ្តើមព្យាបាល) នោះអាចបញ្ជាក់បានថា ការព្យាបាលអាចបរាជ័យ ឬជំងឺស្វាយនោះជាជំងឺស្វាយដែលបានឆ្លងយូរណាស់មកហើយ (ឆ្លងលើសពី ២ឆ្នាំ) ឬក៏អាចឆ្លងជំងឺស្វាយសារជាថ្មីម្តងទៀត។ ទោះបីយ៉ាងណាក៏ដោយ លទ្ធផលតេស្តសេរ៉ូសាស្ត្របែបនេះ មិនអាចបញ្ជាក់ពីមូលហេតុណាមួយដែលបានរៀបរាប់នេះអោយបានពិតប្រាកដបានទេ។ ដូច្នេះ ត្រូវព្យាបាលជំងឺស្វាយជូនអ្នកជំងឺនេះសារជាថ្មី និងធ្វើតេស្តរកមេរោគអេដស៍សារជាថ្មី (ក្នុងករណីលទ្ធផលតេស្តលើកមុន អវិជ្ជមាន)។ បើទោះបីជាការព្យាបាលជំងឺស្វាយដែលឆ្លងថ្មី ត្រូវប្រើប្រាស់ឱសថ Benzathine-Penicillin G 2.4 million units ចាក់សាច់ដុំតែម្តងគត់ក៏ដោយ គ្រូពេទ្យគប្បីផ្តល់ការព្យាបាលជូនអ្នកជំងឺដែលមានស្ថានភាពបែបនេះ ដោយឱសថ Benzathine-Penicillin G 2.4 million units ចាក់សាច់ដុំ មួយដងក្នុងមួយសប្តាហ៍ រយៈពេលបីសប្តាហ៍បន្តបន្ទាប់គ្នា ដើម្បីអោយការព្យាបាលនេះអាចមានប្រសិទ្ធិភាពចំពោះជំងឺស្វាយដែលបានឆ្លងយូរណាស់មកហើយ និងជំងឺស្វាយដែលបានព្យាបាលបរាជ័យពីលើកមុន។
- <u>កំណត់សំគាល់</u> : ជាទូទៅ តេស្ត RPR qualitative ត្រឡប់ទៅជា អវិជ្ជមាន វិញក្រោយពីការព្យាបាលទទួលបានជោគជ័យ ក៏ប៉ុន្តែចំពោះអ្នកជំងឺខ្លះ RPR titre អាចស្ថិតនៅក្នុងកំរិតទាបអស់រយៈពេលដ៏យូរ ឬជួនកាលអស់មួយជីវិត។

## ៤.៣ ការព្យាបាល និងការពិនិត្យតាមដានចំពោះទារក

### <u>៤.៣.១ ការធ្វើរោគវិនិច្ឆ័យជំងឺស្វាយពីកំណើតចំពោះទារកដែលទើបនឹងកើតនៅសេវាសំរាលកូន</u>

- ការធ្វើរោគវិនិច្ឆ័យជំងឺស្វាយពីកំណើតមានការលំបាកស្មុកស្មាញណាស់ ដោយសារតែការផ្ទេរអង្គបដិបក្ខប្រាណពីម្តាយមកទារកតាមរយៈសុក (transplacental transfer of maternal antibodies to the fetus) ។ ការផ្ទេរអង្គបដិបក្ខប្រាណពីម្តាយទៅកូននេះ ធ្វើអោយមានការលំបាកក្នុងការបកស្រាយលទ្ធផលតេស្តសេរ៉ូសាស្ត្រចំពោះជំងឺស្វាយលើទារកដែលទើបនឹងកើត។ យើងក៏មិនត្រូវយកឈាមពីទងសុកទារកទៅ

ធ្វើតេស្តដែរ ដោយសារឈាមនោះអាចនឹងមានឆ្លងមេរោគស្វាយពីឈាមរបស់ម្តាយ។ ដូច្នេះគ្មានតេស្តណាមួយសំរាប់ប្រើប្រាស់ស្រាវជ្រាវរកមេរោគស្វាយពីកំណើតចំពោះទារកនៅឡើយទេ។ ការធ្វើរោគវិនិច្ឆ័យជំងឺនេះពឹងផ្អែកទៅលើការពិនិត្យរោគសញ្ញាគ្លីនិក និងប្រវត្តិជំងឺនិងការព្យាបាលរបស់ម្តាយ។

- ត្រូវពិនិត្យអោយបានហ្មត់ចត់ចំពោះទារកដែលទើបនឹងកើត ដើម្បីរករោគសញ្ញាដែលអាចសង្ស័យថាជា ជំងឺស្វាយពីកំណើត :
  - ប្រសិនបើមានរោគសញ្ញាណាមួយខាងក្រោមនេះ សូមបញ្ជូនទារកទៅសេវាឯកទេសថែទាំព្យាបាលកុមារ ឬមន្ទីរពេទ្យបង្អែកណាមួយ :
    - ទារកកើតមិនគ្រប់ខែ ឬទារកកើតមកមានទំងន់តិចជាងធម្មតា
    - មានហូរសំបោរ ឬទឹករងៃពីច្រមុះរ៉ាំរ៉ៃ
    - សម្បុរលឿង (ភ្នាសសើមនៅភ្នែកលឿង)
    - ថ្លើម, អណ្តើក ឬកូនកណ្តុររីកធំ
    - កន្ទួលរមាស់ស្បែក ជួនកាលស្បែកស្ងួត ឬមានពងទឹកតូចៗ ឬបែកស្រកា ឬសើមៗ ជាពិសេសនៅដៃ, ជើង ឬនៅបរិវេណជុំវិញមាត់ ឬរន្ធគូថ
    - ទ្រង់ទ្រាយឆ្អឹងនៅច្រមុះ ឬជើងមានលក្ខណៈមិនធម្មតា-វៀច។
  - បើទោះបីជាទារកដែលទើបនឹងកើតគ្មានរោគសញ្ញាណាមួយខាងលើនេះក៏ដោយ ប៉ុន្តែទារកនោះកើតចេញពីម្តាយដែលមានតេស្តស្វាយ វិជ្ជមាន យើងត្រូវតែព្យាបាលជំងឺស្វាយចំពោះទារកដោយឱសថ Benzathine-Penicillin ចាក់សាច់ដុំតែម្តងគត់។
- បន្ទាប់មក ត្រូវបញ្ជូនទារកទៅសេវាចាក់ថ្នាំបង្ការ និងធ្វើតេស្ត DNA-PCR រកមេរោគអេដស៍។

## ៤.៣.២ ការព្យាបាលជំងឺស្វាយចំពោះទារកដែលទើបនឹងកើត

- ត្រូវព្យាបាលជំងឺស្វាយដោយឱសថ Benzathine-Penicillin G 50,000 units/Kg. ចាក់សាច់ដុំតែម្តងគត់ ចំពោះទារកដែលទើបនឹងកើតចេញពីម្តាយដែលមានតេស្តមេរោគស្វាយ វិជ្ជមាន បើទោះបីជាទារកដែលទើបនឹងកើតនោះ គ្មានរោគសញ្ញាជំងឺស្វាយពីកំណើតក៏ដោយ។

## ៤.៣.៣ ការពិនិត្យតាមដានកុមារ

- ទោះបីជាទារកឆ្លងមេរោគស្វាយពីម្តាយ ហើយគ្មានរោគសញ្ញានៅពេលទើបនឹងកើតក៏ដោយ ក៏រោគសញ្ញាគ្លីនិកនៃជំងឺស្វាយពីកំណើតអាចនឹងលេចចេញនៅពេលក្រោយមកទៀត។
- ដូច្នេះ រាល់ពេលដែលម្តាយនាំកុមារមកទទួលការចាក់ថ្នាំបង្ការ (សប្តាហ៍ទី ៦, ១០, ១៤ និងនៅខែទី ៩) គ្រូពេទ្យត្រូវពិនិត្យកុមាររករោគសញ្ញាគ្លីនិកនៃជំងឺស្វាយពីកំណើតដូចជា : មានហូរសំបោរ ឬទឹករងៃពីច្រមុះ រាំរ៉ៃ, សម្បុរលឿង (ភ្នាសសើមនៅភ្នែកលឿង), ថ្លើម, អណ្តើក ឬកូនកណ្តុររីកធំ, កន្ទួលរមាស់ស្បែក ជួនកាលស្បែកស្ងួត ឬមានពងទឹកតូចៗ ឬបែកស្រកា ឬសើមៗ ជាពិសេសនៅដៃ, ជើង ឬនៅបរិវេណជុំវិញមាត់ ឬរន្ធគូថ។ ប្រសិនបើមានរោគសញ្ញាណាមួយ ត្រូវបញ្ជូនកុមារទៅសេវាឯកទេសថែទាំព្យាបាលកុមារ ឬមន្ទីរពេទ្យបង្អែកដែលនៅជិតបំផុត ដើម្បីធ្វើការវាយតំលៃរោគវិនិច្ឆ័យជាបន្ទាន់និងទទួលការព្យាបាលភ្លាមៗ។
- ***<u>កំណត់ចំណាំ</u>** : ដើម្បីជួយសំរួលដល់ការពិនិត្យតាមដានកុមារនិងម្តាយ អ្នកផ្តល់សេវាថែទាំសុខភាពនៅសេវាសំរាលកូន និងសេវាចាក់ថ្នាំបង្ការត្រូវសរសេរកំណត់ចំណាំ **"ម្តាយ RPR (+) និងកុមារបានទទួលការព្យាបាលហើយ"** នៅលើប័ណ្ណចាក់ថ្នាំបង្ការ ដើម្បីអោយអ្នកផ្តល់សេវាពិនិត្យតាមដានរករោគសញ្ញាគ្លីនិករៀងរាល់ពេលដែលកុមារមកចាក់ថ្នាំបង្ការ និងដើម្បីធ្វើតេស្ត RPR titre ចំពោះម្តាយឡើងវិញនៅខែទី ៩ ពេលម្តាយនាំកូនមកចាក់ថ្នាំបង្ការជំងឺកញ្ជ្រិល។*

# ៥ ការផ្គត់ផ្គង់សំភារៈ បរិក្ខារ និងប្រតិករ

សំភារៈសំរាប់ធ្វើតេស្ត RPR នឹងត្រូវបានផ្គត់ផ្គង់ជូនដល់មន្ទីរពិសោធន៍នៃមន្ទីរពេទ្យបង្អែក និងអតីតមន្ទីរពេទ្យស្រុក តាមរយៈមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ, មជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក និងតាមរយៈអង្គការអន្តរជាតិ-អង្គការមិនមែនរដ្ឋាភិបាលជាដៃគូ។ ក្រសួងសុខាភិបាលនឹងផ្គត់ផ្គង់ឱសថ បរិក្ខារ និងប្រតិករ (Rapid test "Bioline", RPR test) តាមរយៈឃ្លាំងឱសថកណ្តាលជូនដល់ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ ដើម្បីចែកចាយបន្ត។

ឱសថ បរិក្ខារ និងប្រតិករមួយចំនួនសមស្របត្រូវបានរក្សាទុកនៅក្នុងឃ្លាំងស្តុកនៃមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ សំរាប់ការផ្គត់ផ្គង់ជាបន្ទាន់ ក្នុងករណីមានការកើនឡើងនូវតំរូវការ ឬការដាច់ស្តុក ដោយថាហេតុក្នុងចន្លោះពេលនៃការផ្គត់ផ្គង់ដោយឃ្លាំងឱសថកណ្តាល។

## ៦ ការផ្សព្វផ្សាយពត៌មាន, អប់រំ និងទំនាក់ទំនង

រៀងរាល់ពេលពិនិត្យជំងឺ អ្នកផ្តល់សេវាថែទាំត្រូវអប់រំអតិថិជនអំពីការបង្ការជំងឺកាមរោគ-អេដស៍ និងការធ្វើតេស្តរកមេរោគអេដស៍, បង្ហាញប្រាប់អំពីរបៀបប្រើប្រាស់ស្រោមអនាម័យ, ប្រាប់អំពីការប្រើប្រាស់ឱសថអោយបានត្រឹមត្រូវ-ទៀងទាត់ និងជាប់លាប់ និងប្រាប់អំពីការអញ្ជើញដៃគូរួមភេទអោយមកទទួលការថែទាំព្យាបាល ។

## ៧ ការពិនិត្យតាមដាន និងរបាយការណ៍

### ៧.១ បញ្ជីសំរង់ពត៌មានអតិថិជនពិនិត្យផ្ទៃពោះមុនពេលសំរាល ( ឧបសម្ព័ន្ធទី៤)

- ត្រូវប្រើប្រាស់បញ្ជីសំរង់ពតិមានអតិថិជនពិនិត្យផ្ទៃពោះមុនពេលសំរាល ដែលកំពុងប្រើប្រាស់នៅតាមមណ្ឌលសុខភាព, មន្ទីរពេទ្យបង្អែក និងគ្លីនិកអង្គការមិនមែនរដ្ឋាភិបាលដើម្បីកត់ត្រាពតិមានសង្ខេបរបស់ស្ត្រីមានផ្ទៃពោះ នៅរាល់ពេលគាត់ទៅពិនិត្យសុខភាព ។
- ចំពោះសេវាសុខាភិបាលនៅតាមស្រុកប្រតិបត្តិដែលកំពុងអនុវត្តយុទ្ធសាស្ត្រនៃការឆ្លើយតបរួមគ្នា ចំពោះការបង្ការ និងថែទាំព្យាបាលជំងឺអេដស៍-កាមរោគ និងសុខភាពបន្តពូជ (Linked Response for Prevention, Care, and Treatment of HIV/AIDS and Sexual and Reproductive Health Issues) ត្រូវប្រើប្រាស់សៀវភៅចុះបញ្ជីស្ត្រីមានផ្ទៃពោះដែលស្ម័គ្រចិត្តទទួលការផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមរកមេរោគអេដស៍ នៅផ្នែកពិនិត្យផ្ទៃពោះ ដែលបានផ្តល់ជូនដោយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ។
- បញ្ចូលបន្ថែមខ្ទង់ (column) ចំនួនបួន : “ធ្វើតេស្តរកមេរោគស្វាយដោយ Rapid test និងលទ្ធផលតេស្ត” និង “ធ្វើតេស្តរកមេរោគស្វាយដោយ RPR test និងលទ្ធផលតេស្ត” ទៅក្នុងបញ្ជីសំរង់ពតិមានអតិថិជន ពិនិត្យផ្ទៃពោះមុនពេលសំរាល (សូមមើលឧបសម្ព័ន្ធទី៤) ដើម្បីបញ្ជាក់ថា ស្ត្រីមានផ្ទៃពោះនោះបានធ្វើតេស្តស្រាវជ្រាវរកមេរោគស្វាយ និងបញ្ជាក់ពីលទ្ធផលតេស្ត ផងដែរ។ ប្រសិនបើស្ត្រីនោះបានធ្វើតេស្ត ត្រូវគូសសញ្ញា ✓ នៅក្នុងខ្ទង់ “ធ្វើតេស្តរកមេរោគស្វាយ” ។ ចំពោះលទ្ធផលតេស្ត វិជ្ជមាន ឬ អវិជ្ជមាន ត្រូវសរសេរនៅក្នុងខ្ទង់ “លទ្ធផលតេស្ត” ដោយគូសសញ្ញា (+) ឬ (-) ។
- ត្រូវរក្សាបញ្ជីសំរង់ពតិមាននោះនៅសេវាពិនិត្យផ្ទៃពោះមុនពេលសំរាល ដើម្បីបង្ការមិនអោយបាត់បង់ និងងាយស្រួលរកពតិមានទាំងនោះឡើងវិញផង ។

## ៧.២ សន្លឹកសំរង់ពត៌មានរបស់ស្ត្រីពិនិត្យផ្ទៃពោះមុនពេលសំរាល ( ឧបសម្ព័ន្ធទី៥)

- ត្រូវប្រើប្រាស់សន្លឹកសំរង់ពត៌មានរបស់ស្ត្រីពិនិត្យផ្ទៃពោះមុនពេលសំរាល ដែលកំពុងប្រើប្រាស់នៅតាមមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក ដើម្បីកត់ត្រាទុករាល់ពត៌មានដែលទាក់ទងនឹងស្ត្រីមានផ្ទៃពោះនោះ។
- ត្រូវបញ្ចូលសន្លឹកបន្ថែម (additional sheet) ស្តីពីការស្រាវជ្រាវរកជំងឺស្វាយ ភ្ជាប់ជាមួយនឹងសន្លឹកសំរង់ពត៌មានរបស់ស្ត្រីពិនិត្យផ្ទៃពោះ ដើម្បីកត់ត្រាទុកនូវពត៌មានស្តីអំពីការធ្វើតេស្តរកមេរោគស្វាយ និងការព្យាបាលជូនស្ត្រីនោះ។
- ត្រូវរក្សាសន្លឹកសំរង់ពត៌មាននោះនៅសេវាពិនិត្យផ្ទៃពោះមុនពេលសំរាល ដើម្បីបង្ការមិនអោយបាត់បង់ និងងាយស្រួលរកពត៌មានទាំងនោះឡើងវិញផង។

## ៧.៣ សៀវភៅសុខភាពមាតា ( ឧបសម្ព័ន្ធទី៦)

- ត្រូវប្រើប្រាស់ "សៀវភៅសុខភាពមាតា" ដែលមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែកបានប្រគល់ជូនដល់ស្ត្រីដែលមកពិនិត្យផ្ទៃពោះ ដើម្បីអោយអ្នកផ្តល់សេវាថែទាំសុខភាពកត់ត្រាទុករាល់ពត៌មានរបស់ស្ត្រីនោះនៅរៀងរាល់ពេលមានផ្ទៃពោះម្តងៗ។
- ត្រូវបញ្ចូលសន្លឹកបន្ថែម (additional sheet) ស្តីពីការស្រាវជ្រាវរកជំងឺស្វាយ ទៅក្នុងសៀវភៅសុខភាពមាតា ដើម្បីកត់ត្រាទុកនូវពត៌មានស្តីអំពីការធ្វើតេស្តរកមេរោគស្វាយ និងការព្យាបាលជូនស្ត្រីនោះ។
- "សៀវភៅសុខភាពមាតា" ត្រូវរក្សាទុកដោយស្ត្រីខ្លួនឯងផ្ទាល់ ហើយត្រូវយកមកជាប់នឹងខ្លួនគាត់ នៅរាល់ពេលដែលគាត់មកពិនិត្យផ្ទៃពោះមុនពេលសំរាលនៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យបង្អែក ហើយត្រូវប្រើប្រាស់សៀវភៅនេះរាល់ពេលដែលគាត់មានផ្ទៃពោះ បើទោះបីជានៅពេលគាត់ឈឺពោះសំរាលកូនក៏ដោយ។ វិធីនេះធ្វើអោយអ្នកផ្តល់សេវាថែទាំសុខភាពអាចទទួលបាននូវពត៌មានផ្សេងៗដែលទាក់ទងនឹងផ្ទៃពោះរបស់គាត់ នៅពេលដែលគាត់មកពិនិត្យសុខភាពម្តងៗ។

## ៧.៤ របាយការណ៍ ( ឧបសម្ព័ន្ធទី៧)

- មណ្ឌលសុខភាព, មន្ទីរពេទ្យបង្អែក, គ្លីនិកសុខភាពគ្រួសារ និងគ្លីនិកអង្គការមិនមែនរដ្ឋាភិបាល ត្រូវធ្វើរបាយការណ៍ស្តីអំពីការធ្វើតេស្តស្រាវជ្រាវរកជំងឺស្វាយ រៀងរាល់ត្រីមាសមកផ្នែកគ្រប់គ្រងទិន្នន័យនៃមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ។ បន្ទាប់ពីការបូកសរុប របាយការណ៍នេះនឹងត្រូវបានផ្សព្វផ្សាយជូនដល់ស្ថាប័នពាក់ពន្ធ័នានា ជាពិសេសមជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក។
- ត្រូវប្រើប្រាស់សន្លឹកបន្ថែម (additional sheet) ស្តីពីរបាយការណ៍នៃការធ្វើតេស្តស្រាវជ្រាវរកជំងឺស្វាយ (សូមមើលឧបសម្ព័ន្ធទី៧) ភ្ជាប់មកជាមួយនឹងរបាយការណ៍ប្រចាំត្រីមាសស្តីពីករណីជំងឺកាមរោគសំរាប់មណ្ឌលសុខភាព មន្ទីរពេទ្យបង្អែក, គ្លីនិកសុខភាពគ្រួសារ និងគ្លីនិកអង្គការមិនមែនរដ្ឋាភិបាលដែលមានសេវាធ្វើតេស្តស្រាវជ្រាវរកជំងឺស្វាយចំពោះស្ត្រីមានផ្ទៃពោះមុនពេលសំរាល។

## ឧបសម្ព័ន្ធទី១ : ការធ្វើតេស្តស្រាវជ្រាវរកមេរោគបង្កជំងឺស្វាយចំពោះស្ត្រីមានផ្ទៃពោះ

ស្ត្រីមកពិនិត្យផ្ទៃពោះជាលើកដំបូង (ANC)

↓

តើមានដំបៅឬពងទឹក/បែក នៅប្រដាប់បន្តពូជដែរឬទេ?

- មាន → **ប្រើគំនូសបំព្រួញស្តីពីការថែទាំព្យាបាលដំបៅលើប្រដាប់បន្តពូជ**
- គ្មាន → **Rapid test**

**Rapid test**

- អវិជ្ជមាន →
  - អប់រំ និងផ្តល់ប្រឹក្សា
  - ជំរុញអោយប្រើប្រាស់ស្រោមអនាម័យ និងផ្តល់ស្រោមជូនគាត់
  - ជំរុញអោយធ្វើតេស្តរកមេរោគអេដស៍
- វិជ្ជមាន → **RPR test**

**RPR test**

- អវិជ្ជមាន → (ដូចខាងលើ)
- វិជ្ជមាន →

**ព្យាបាលជំងឺស្វាយ**

- Benzathine-Penicillin G 2.4 លាន units ចាក់សាច់ដុំតែម្តងគត់
- អប់រំ និងផ្តល់ប្រឹក្សា
- ជំរុញអោយប្រើប្រាស់ស្រោមអនាម័យ និងផ្តល់ស្រោមជូនគាត់
- គ្រប់គ្រង និងថែទាំព្យាបាលដៃគូរួមភេទ
- ជំរុញអោយធ្វើតេស្តរកមេរោគអេដស៍

**RPR titre (quantitative)** ដើម្បីរក្សាលទ្ធផលតេស្តនោះ ជាគោល (baseline)

*តាមដានលទ្ធផលតេស្តក្នុងរយៈពេលពី ៦ ទៅ ១២ ខែក្រោយ ។*
*ឧ. នៅខែទី ៩បន្ទាប់ពីសំរាលកូន**

លទ្ធផលតេស្ត **RPR titre** ធ្លាក់ចុះស្មើ ឬលើសពី 2 titres (≥ 2 titres)**

- អប់រំ និងផ្តល់ប្រឹក្សា
- ជំរុញអោយប្រើប្រាស់ស្រោមអនាម័យ និងផ្តល់ស្រោមជូនគាត់
- ជំរុញអោយធ្វើតេស្តរកមេរោគអេដស៍ ( ប្រសិនបើមិនទាន់ធ្វើ)
- ត្រូវព្យាបាលជំងឺស្វាយជូនដៃគូរួមភេទរបស់គាត់ ប្រសិនបើដៃគូនោះមិនទាន់បានទទួលការព្យាបាលនៅឡើយ ។

លទ្ធផលតេស្ត **RPR titre** កើនឡើង ឬមិនប្រែប្រួល ឬធ្លាក់ចុះតិចជាង 2 titres (≤ 2 titres)

ការព្យាបាលអាចបរាជ័យ ឬស្ត្រីអាចឆ្លងជំងឺស្វាយជាថ្មី ឬក៏ជាជំងឺស្វាយដែលបានឆ្លងយូរណាស់មកហើយ ។ ត្រូវ **ព្យាបាលជំងឺស្វាយ** សារជាថ្មីឡើងវិញ រយៈពេលបីសប្តាហ៍ :

- Benzathine-Penicillin G 2.4 លាន units ចាក់សាច់ដុំមួយដងក្នុង ១សប្តាហ៍ រយៈពេលបីសប្តាហ៍
- ត្រូវលើកទឹកចិត្តអោយស្ត្រីធ្វើតេស្តរកមេរោគអេដស៍
- ត្រូវព្យាបាលជំងឺស្វាយជូនដៃគូរួមភេទរបស់គាត់
- ជំរុញអោយប្រើប្រាស់ស្រោមអនាម័យ និងផ្តល់ស្រោមជូនគាត់

* *ម្តាយនាំកូនមកមណ្ឌលសុខភាពឬមន្ទីរពេទ្យបង្អែក ដើម្បីចាក់វ៉ាក់សាំងការពារជំងឺកញ្ជ្រិល ។*

** *ឧ. ធ្លាក់ចុះពី 1:16 មកនៅត្រឹម 1:4*

## ឧបសម្ព័ន្ធទី២ : ការថែទាំព្យាបាលទារកដែលកើតចេញពីម្តាយមានឆ្លងជំងឺស្វាយ




***រោគសញ្ញាគ្លីនិកដែលនាំអោយសង្ស័យថាអាចជាជំងឺស្វាយពីកំណើត (នៅពេលទារកកើតភ្លាម ឬនៅពេលពិនិត្យតាមដាន) :***

- *ទារកកើតមិនគ្រប់ខែ ឬទារកកើតមកមានទំងន់តិចជាងធម្មតា*
- *មានហូរសំបោរ ឬទឹករងៃពីច្រមុះរ៉ាំរ៉ៃ*
- *សម្បុរលឿង (ភ្នាសសើមនៅភ្នែកលឿង)*
- *ថ្លើម, អណ្តើក ឬកូនកណ្តុររីកធំ*
- *កន្ទួលរមាស់ស្បែក ជួនកាលស្បែកស្ងួត ឬមានពងទឹកតូចៗ ឬបែកស្រកា ឬសើមៗ ជាពិសេសនៅដៃ, ជើង ឬនៅបរិវេណជុំវិញមាត់ ឬរន្ធគូថ*
- *ទ្រង់ទ្រាយឆ្អឹងនៅច្រមុះ ឬជើងមានលក្ខណៈមិនធម្មតា-វៀច ។*

**ឧបសម្ព័ន្ធទី៣ : តេស្ត Standard SD Bioline Syphilis 3.0**

សំភារៈដែលត្រូវការសំរាប់ធ្វើតេស្តនេះគឺ Micropipette និង Tips ដែលមានចំណុះ 10ul ។

**ការអនុវត្តន៏ :**

- ដកយកបន្ទះតេស្តចេញពីកញ្ចប់ ហើយដាក់លើកន្លែងដែលមានផ្ទៃរាបស្មើ
- បន្តក់សេរ៉ូមឈាម ឬឈាមសុទ្ធ ចំនួន 10ul ដោយយឺត១ទៅលើកន្លែងសំរាប់ដាក់វត្ថុវិភាគរបស់បន្ទះតេស្ត
- បន្តក់ល្បាយតេស្ត បី ដំណក់ ទៅលើកន្លែងសំរាប់ដាក់វត្ថុវិភាគរបស់បន្ទះតេស្ត
- ពិនិត្យមើលលទ្ធផលតេស្តរយៈពេល ៥ ទៅ ២០ នាទីក្រោយ




**លទ្ធផល អវិជ្ជមាន**

ប្រសិនបើមានលេចចេញបន្ទះឆ្នូតតែមួយ នោះបញ្ជាក់ថា លទ្ធផលតេស្ត “អវិជ្ជមាន”




**លទ្ធផល វិជ្ជមាន**

ប្រសិនបើមានលេចចេញបន្ទះឆ្នូតចំនួន ពីរ (C និង T) នោះបញ្ជាក់ថា លទ្ធផលតេស្ត “វិជ្ជមាន”




**លទ្ធផល មិនអាចកំណត់បាន**

ប្រសិនបើគ្មានលេចចេញបន្ទះឆ្នូតណាមួយទេ បន្ទាប់ពីធ្វើតេស្ត នោះបញ្ជាក់ថា លទ្ធផលតេស្ត “មិនអាចកំណត់បាន”

## ឧបសម្ពន្ធ័ទី៩ : ខ្ទង់បន្ថែមសំរាប់បញ្ជីសំរង់ពត៌មានពិនិត្យផ្ទៃពោះមុនពេលសំរាល (Additional columns to Antenatal Register)

**<u>កំណត់ចំណាំ :</u>**

- ចំពោះសេវាសុខាភិបាលនៅតាមស្រុកប្រតិបត្តិដែលកំពុងអនុវត្តយុទ្ធសាស្រ្តនៃការឆ្លើយតបរួមគ្នា ចំពោះការបង្ការ និងថែទាំព្យាបាលជំងឺអេដស៍-កាមរោគ និងសុខភាពបន្តពូជ (Linked Response for Prevention, Care, and Treatment of HIV/AIDS and Sexual and Reproductive Health Issues) ត្រូវប្រើប្រាស់ **សៀវភៅចុះបញ្ជីស្រ្តីមានផ្ទៃពោះដែលស្ម័គ្រចិត្តទទួលការផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមរកមេរោគអេដស៍ នៅផ្នែកពិនិត្យផ្ទៃពោះ** ដែលបានផ្តល់ជូនដោយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ។
- ត្រូវពិនិត្យរករោគសញ្ញាជំងឺបៅលើប្រដាប់បន្តពូជ និងធ្វើតេស្តស្រាវជ្រាវរកមេរោគស្វាយ ដោយ " Rapid test " (Treponemal test) ចំពោះស្រ្តីមានផ្ទៃពោះទាំងអស់ដែលបានមកពិនិត្យសុខភាពនៅសេវាពិនិត្យផ្ទៃពោះមុនពេលសំរាល។ ប្រសិនបើលទ្ធ ផល Rapid test **វិជ្ជមាន** ត្រូវធ្វើតេស្តបញ្ជាក់ដោយ " RPR test " (Non-treponemal test) ។

| | | | | | | ការធ្វើតេស្តស្រាវជ្រាវរកមេរោគស្វាយ | | | |
|---|---|---|---|---|---|---|---|---|---|
| | | | | | | Rapid test | | RPR test | |
| | | | | | | (+) | (-) | (+) | (-) |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |

**ឧបសម្ព័ន្ធទី៩ : សន្លឹកបន្ថែមសំរាប់សំរង់ពត៌មានពិនិត្យផ្ទៃពោះមុនពេលសំរាល (Additional sheet to Antenatal Record)**

**<u>កំណត់ចំណាំ :</u>** ត្រូវពិនិត្យរករោគសញ្ញាដំបៅលើប្រដាប់បន្តពូជ និងធ្វើតេស្តស្រាវជ្រាវរកមេរោគស្វាយ ដោយ " Rapid test " (Treponemal test) ចំពោះស្រ្តីមានផ្ទៃពោះទាំងអស់ដែលបានមកពិនិត្យសុខភាពនៅសេវាពិនិត្យផ្ទៃពោះមុនពេលសំរាល ។

**<u>៤ ការធ្វើតេស្តស្រាវរកមេរោគស្វាយ</u>** កាលបរិច្ឆេទ....................................

- ពងទឹក/ដំបៅលើប្រដាប់បន្តពូជ **មាន** ☐ **គ្មាន** ☐ មិនបានពិនិត្យ ☐ កំណត់ចំណាំ................................
- Rapid test រកមេរោគស្វាយ (+) ☐ (-) ☐ មិនបានធ្វើ ☐ កំណត់ចំណាំ................................
- RPR test រកមេរោគស្វាយ (+) ☐ (-) ☐ មិនបានធ្វើ ☐ កំណត់ចំណាំ................................
- ប្រតិកម្មជាមួយឱសថ Penicillin **មាន** ☐ **គ្មាន** ☐ មិនដឹងច្បាស់ ☐ កំណត់ចំណាំ................................
- ព្យាបាលជំងឺស្វាយ **មាន** ☐ **គ្មាន** ☐ កំណត់ចំណាំ................................
- RPR titre Baseline..................... មិនបានធ្វើ ☐ កំណត់ចំណាំ................................
  Follow-up..................
  ..................
- អញ្ជើញដៃគូរួមភេទអោយមកព្យាបាល **មាន** ☐ **គ្មាន** ☐ កំណត់ចំណាំ................................
- ដៃគូរួមភេទបានទទួលការព្យាបាល **មាន** ☐ **គ្មាន** ☐ កំណត់ចំណាំ................................
- ទារកបានទទួលការព្យាបាល **មាន** ☐ **គ្មាន** ☐ កំណត់ចំណាំ................................
- បញ្ជូនទៅសេវា PMTCT ប្រសិនបើ មិនទាន់បានធ្វើតេស្តរកមេរោគអេដស៍ **មាន** ☐ **គ្មាន** ☐ កំណត់ចំណាំ................................

***កាលបរិច្ឆេទណាត់ជួបលើកក្រោយទៀត (ប្រសិនបើចាំបាច់)......................................................................***

***<u>កំណត់ចំណាំ :</u>***

*ប្រសិនបើដឹងច្បាស់ថា លទ្ធផល Rapid test **វិជ្ជមាន** ចាប់ពីពេលមានផ្ទៃពោះលើកមុនមក គេមិនចាំបាច់ធ្វើតេស្តនេះសារជាថ្មីឡើងវិញទេ ។ ចូរធ្វើតេស្ត " RPR test " (qualitative និង quantitative) ក្នុងពេលដំណាលគ្នាតែម្តង ។*

## ឧបសម្ព័ន្ធទី៦ : សន្លឹកបន្ថែមសំរាប់សៀវភៅពិនិត្យសុខភាពមាតា (Additional sheet to Mother Health Record's Book)

**<u>កំណត់ចំណាំ :</u>** ទំរង់សំរង់ពតិមាននេះគឺជាសន្លឹកបន្ថែមទៅក្នុងសៀវភៅសុខភាពមាតា។

**<u>ការធ្វើតេស្តស្រាវជ្រាវរកមេរោគស្វាយ</u>** កាលបរិច្ឆេទ.....................................

- ពងទឹក/ដំបៅលើប្រដាប់បន្តពូជ **មាន** ☐ **គ្មាន** ☐ មិនបានពិនិត្យ ☐ កំណត់ចំណាំ................................
- Rapid test រកមេរោគស្វាយ (+) ☐ (-) ☐ មិនបានធ្វើ ☐ កំណត់ចំណាំ................................
- RPR test រកមេរោគស្វាយ (+) ☐ (-) ☐ មិនបានធ្វើ ☐ កំណត់ចំណាំ................................
- ប្រតិកម្មជាមួយឱសថ Penicillin **មាន** ☐ **គ្មាន** ☐ មិនដឹងច្បាស់ ☐ កំណត់ចំណាំ................................
- ព្យាបាលជំងឺស្វាយ **មាន** ☐ **គ្មាន** ☐ កំណត់ចំណាំ................................
- RPR titre Baseline………………… មិនបានធ្វើ ☐ កំណត់ចំណាំ................................
  Follow-up………………
  ………………
- អញ្ជើញដៃគូរួមភេទអោយមកព្យាបាល **មាន** ☐ **គ្មាន** ☐ កំណត់ចំណាំ................................
- ដៃគូរួមភេទបានទទួលការព្យាបាល **មាន** ☐ **គ្មាន** ☐ កំណត់ចំណាំ................................
- ទារកបានទទួលការព្យាបាល **មាន** ☐ **គ្មាន** ☐ កំណត់ចំណាំ................................
- បញ្ជូនទៅសេវា PMTCT ប្រសិនបើមិនទាន់បានធ្វើតេស្តរកមេរោគអេដស៍ **មាន** ☐ **គ្មាន** ☐ កំណត់ចំណាំ................................

***កាលបរិច្ឆេទណាត់ជួបលើកក្រោយទៀត (ប្រសិនបើចាំបាច់)*****.....................................................................**

***<u>កំណត់ចំណាំ :</u>***

*ប្រសិនបើដឹងច្បាស់ថា លទ្ធផល Rapid test* ***វិជ្ជមាន*** *ចាប់ពីពេលមានផ្ទៃពោះលើកមុនមក គេមិនចាំបាច់ធ្វើតេស្តនេះសារជាថ្មីឡើងវិញទេ។ ចូរធ្វើតេស្ត " RPR test " (qualitative និង quantitative) ក្នុងពេលដំណាលគ្នាតែម្តង។*

## ឧបសម្ព័ន្ធទី៧ : របាយការណ៍ប្រចាំត្រីមាសស្តីពីករណីជំងឺកាមរោគ

**កំណត់ចំណាំ :** ទំរង់សំរង់ពត៌មាននេះគឺជាសន្លឹកបន្ថែមស្តីអំពីការធ្វើតេស្តស្រាវជ្រាវរកមេរោគស្វាយចំពោះស្ត្រីមានផ្ទៃពោះ ដែលភ្ជាប់ជាមួយនឹងរបាយការណ៍ប្រចាំត្រីមាសស្តីពីករណីជំងឺកាមរោគដែលបញ្ជូនមកពីគ្លីនិកសុខភាពគ្រួសារ ឬមណ្ឌលសុខភាព ដែលមានសេវានេះ ។

### ការធ្វើតេស្តស្រាវជ្រាវរកមេរោគស្វាយចំពោះស្ត្រីមានផ្ទៃពោះ

**ខែ.................................................. ត្រីមាសទី............................................ ឆ្នាំ ២០..........**

**ឈ្មោះគ្លីនិកសុខភាពគ្រួសារ ឬមន្ទីរពេទ្យបង្អែក ឬមណ្ឌលសុខភាព.......................................................................................**

**ស្រុកប្រតិបត្តិ................................................................. ខេត្ត..................................................................................**

| | | ការបែងចែកតាមអាយុ | | | សរុប |
|---|---|---|---|---|---|
| **ការធ្វើតេស្តរកមេរោគស្វាយ** | | **តិចជាង ១៥ ឆ្នាំ** | **១៥-៤៩ ឆ្នាំ** | **លើសពី ៥០ឆ្នាំ** | |
| ចំនួនស្ត្រីទាំងអស់ដែលមកពិនិត្យផ្ទៃពោះលើកទី១ នៅសេវាពិនិត្យផ្ទៃពោះមុនពេលសំរាល | | | | | |
| | ចំនួនស្ត្រីទាំងអស់ដែលបានធ្វើ *Rapid test* | | | | |
| | ចំនួន *Rapid test (+)* | | | | |
| | ចំនួនស្ត្រីទាំងអស់ដែលបានធ្វើ *RPR qualitative test* | | | | |
| | ចំនួន *RPR test (+)* | | | | |
| ចំនួនស្ត្រីមកពិនិត្យផ្ទៃពោះ ដែលបានព្យាបាលជំងឺស្វាយ | | | | | |
| ចំនួនស្ត្រីមានជំងឺស្វាយដែលបានធ្វើ *RPR quantitative test (titre)* | | | | | |
| | ចំនួនស្ត្រីធ្វើតេស្ត *RPR- Titre - baseline* | | | | |
| | ចំនួនស្ត្រីធ្វើតេស្ត *RPR- Titre - follow up* | | | | |
| ចំនួនសរុប ដៃគូដែលបានទទួលការព្យាបាលជំងឺស្វាយ | | | | | |
| ចំនួនសរុប ទារកដែលបានទទួលការព្យាបាលជំងឺស្វាយ | | | | | |

## ឧបសម្ព័ន្ធទី៨ : ការគ្រប់គ្រងថែទាំអ្នកជំងឺដែលមានប្រតិកម្មជាមួយឱសថ (Management of anaphylaxis)

ប្រតិកម្មជាមួយនឹងឱសថ (Anaphylaxis) អាចកើតមានឡើងដោយចៃដន្យ នៅគ្លីនិកពេលដែលអ្នកជំងឺទទួលការព្យាបាល ។ គ្រូពេទ្យត្រូវធ្វើការសង្គ្រោះអ្នកជំងឺជាបន្ទាន់ភ្លាមៗ នៅពេលដែលគាត់មានប្រតិកម្មជាមួយនឹងឱសថព្យាបាល ។

ដូច្នេះ ត្រូវតែមានឱសថ Adrenaline សំរាប់ប្រើប្រាស់ភ្លាមៗ ប្រសិនបើករណីនេះកើតមានឡើង នៅពេលណាដែលគ្រូពេទ្យចាក់វ៉ាក់សាំង ឬប្រើឱសថចាក់ជូនអ្នកជំងឺ ។

### ១- រោគសញ្ញានៃការមានប្រតិកម្មជាមួយនឹងឱសថ

អ្នកជំងឺអាចដឹងថាខ្លួនមានប្រតិកម្មជាមួយនឹងឱសថ នៅពេលដែលគាត់មានរោគសញ្ញាដូចតទៅ :

- ចាប់ផ្តើមតឹង-ថប់ដង្ហើមភ្លាមៗ (wheeze) - ពិបាកដកដង្ហើម
- ហើម-ហើមមុខ, បបូរមាត់ និងអណ្តាត
- ឡើងស្វាយ-ស្វាយបបូរមាត់ និងម្រាមដៃ
- ជីពចរដើរញាប់
- សំពាធឈាមចុះទាប
- ឡើងកន្ទួល-រមាស់ ដែលកើតឡើងយ៉ាងឆាប់រហ័សជាមួយរោគសញ្ញាខាងលើ ។

### ២- ការគ្រប់គ្រងថែទាំជាបន្ទាន់ចំពោះអ្នកជំងឺដែលមានប្រតិកម្មជាមួយឱសថ

- ដាក់អ្នកជំងឺអោយដេកសណ្តូកផ្អៀងមកខាងឆ្វេង
- រៀបចំសំរួលអោយមានខ្យល់ដកដង្ហើម ប្រសិនបើអ្នកជំងឺឈប់ដកដង្ហើម ឬជីពចរនៅសសៃរបំពង់ក (Carotide pulse) មិនអាចស្ទាបឃើញ ត្រូវចាប់ផ្តើមជួយសង្គ្រោះដល់បេះដូង-សួត ជាបន្ទាន់ភ្លាម ដើម្បីអោយសរីរាង្គនេះដំណើរការឡើងវិញ
- ស្នើសុំជំនួយសង្គ្រោះបន្ទាន់ភ្លាមៗ ។

### ៣- ការប្រើប្រាស់ឱសថ Adrenaline

- ត្រូវចាក់ឱសថ ចូលក្នុងសាច់ដុំអោយជ្រៅ ដោយប្រើសឺរ៉ាំងចំណុះ ១ ម.ល. និងម្ជុលលេខ ២៣ G ។

| Dose of Adrenaline = 0.01ml/kg* | |
|---|---|
| **AGE/WEIGHT** | **DOSE OF ADRENALINE (ml of 1:1000)** |
| 1-2 years (approx 3 - 10 kg) | 0.03 - 0.1 ml |
| 2-3 years (approx 10 kg) | 0.1 ml |
| 4-6 years (approx 15 kg) | 0.15 ml |
| 7-10 years (approx 20 kg) | 0.2 ml |
| 11-12 years (approx 25 - 30 kg) | 0.25 - 0.3 ml |
| 12 - 14 years (approximately 40 kg) | 0.4 ml |
| **Adult** | **0.5 ml** |

- គ្រូពេទ្យត្រូវថ្លឹងកុមារ ឬពិនិត្យមើលទំងន់កុមារកាលពីលើកមុន នៅក្នុងសៀវភៅកត់ត្រាពតិមានរបស់អ្នកជំងឺ ក៏ប៉ុន្តែមិនត្រូវធ្វើអោយមានការយឺតយ៉ាវដល់ការសង្គ្រោះទារកទេ។
- ត្រូវប្រើឱសថ Adrenaline ជាបន្តបន្ទាប់រយៈពេល ៥ នាទីម្តង ចំពោះមនុស្សពេញវ័យ ឬ ១០ ទៅ ១៥ នាទីម្តង ចំពោះកុមាររហូតទាល់តែមានសភាពធូរស្រាលឡើងវិញ។

## ៤- <u>ការថែទាំបន្ថែមក្រោយពីការចាប់ផ្តើមចាក់ឱសថ Adrenaline</u>

- ចាប់ផ្តើមចាក់បញ្ចូលសេរ៉ូមប្រៃភ្លាមៗ
- ដាក់ខ្យល់អុកស៊ីសែន ១00% ដោយពាក់ម៉ាស់លើមុខអ្នកជំងឺ (face-mask) ក្នុងចំណុះ ៨ លីត្រក្នុង ១ នាទី ហើយរក្សាអោយខ្យល់អាចចេញចូលតាមផ្លូវដកដង្ហើមបានល្អ
- បញ្ជូនអ្នកជំងឺតាមរថយន្តសង្គ្រោះបន្ទាន់ ប្រសិនបើអាចធ្វើទៅបាន។ ដាក់អ្នកជំងឺអោយសំរាកព្យាបាលនៅក្នុងមន្ទីរពេទ្យ ដើម្បីពិនិត្យតាមដានបន្ត និងផ្តល់ការថែទាំព្យាបាល
- ពិនិត្យតាមដានការព្យាបាល និងសញ្ញាផ្សេងៗ ដូចជា សម្ពាធឈាម, ចង្វាក់បេះដូង, សីតណ្ហភាព, ចង្វាក់ដង្ហើម, កំហាប់អុកស៊ីសែន ។ល។ រៀងរាល់រយៈពេល ១០-១៥ នាទីម្តង និងកត់ត្រាលទ្ធផលទុក។

## ឧបសម្ព័ន្ធទី៩ : គំនូសបំព្រួញស្តីពីដំបៅនៅលើប្រដាប់បន្តពូជ (Genital Ulcer Management)

## ការថែទាំព្យាបាលដោយពឹងផ្អែកលើចង្កោមរោគសញ្ញា ( គ្មានមន្ទីរពិសោធន៍)

អ្នកជំងឺត្អូញត្អែរថាមានពងទឹកឬដំបៅនៅលើប្រដាប់បន្តពូជ

↓

ស្រង់ប្រវត្តិនិងពិនិត្យអ្នកជំងឺ

↓

តើមានពងទឹក/បែក ដែរ ឬទេ?

- មាន ↓
  - **ព្យាបាលជំងឺពងទឹក/បែក**
  - អប់រំដើម្បីអោយអ្នកជំងឺផ្លាស់ប្តូរការប្រព្រឹត្ត
  - ជំរុញការប្រើប្រាស់ និងផ្តល់ស្រោមអនាម័យ
  - គ្រប់គ្រងថែទាំព្យាបាលដៃគូរួមភេទ
  - ផ្តល់ប្រឹក្សាធ្វើតេស្តឈាម រកមេរោគអេដស៍
- ទេ → តើមានដំបៅ ពិតប្រាកដែរឬទេ?
  - មាន ↓
    - **ព្យាបាលជំងឺស្វាយ និងជំងឺ Chancroid**
    - អប់រំដើម្បីអោយអ្នកជំងឺផ្លាស់ប្តូរការប្រព្រឹត្ត
    - ជំរុញការប្រើប្រាស់ និងផ្តល់ស្រោមអនាម័យ
    - គ្រប់គ្រងថែទាំព្យាបលដៃគូរួមភេទ
    - ផ្តល់ប្រឹក្សាធ្វើតេស្តឈាម រកមេរោគអេដស៍
    - ព្យាបាលជំងឺហើមគ្រលៀន ដោយផ្អែកលើលក្ខណៈអេពីដេមីសាស្ត្រ ប្រសិនបើអ្នកជំងឺមិនធូរស្រាលក្នុងពេលមកតាមដាន ឬការមកពិនិត្យលើកដំបូង
    - ប្រាប់អ្នកជំងឺអោយវិលត្រឡប់មកជួបវិញ បើចាំបាច់ ។
  - ទេ →
    - អប់រំអ្នកជំងឺអោយផ្លាស់ប្តូរការប្រព្រឹត្ត
    - ជំរុញការប្រើប្រាស់ និង ផ្តល់ស្រោមអនាម័យ
    - **ផ្តល់ប្រឹក្សាធ្វើតេស្តឈាម រកមេរោគអេដស៍**

# ការថែទាំព្យាបាលដោយពឹងផ្អែកលើតេស្តមន្ទីរពិសោធន៍



## ឧបសម្ព័ន្ធទី១០ : ទីកន្លែងដែលបានដំណើរការសេវាធ្វើតេស្តឈាមរកមេរោគស្វាយចំពោះស្ត្រីមានផ្ទៃពោះ

នៅក្នុងឆ្នាំ ២០០៨ នេះ មានសេវាថែទាំសុខភាពចំនួន ៣៤ ដែលបានអោយចាប់ផ្តើមដំណើរការសេវាធ្វើតេស្តឈាមរកមេរោគស្វាយចំពោះស្ត្រីមានផ្ទៃពោះ ដោយការធ្វើ “RAPID TEST” :

**សេវាថែទាំសុខភាពដែលកំពុងដំណើរការធ្វើតេស្តឈាមរកមេរោគស្វាយ (បន្តសកម្មភាពនៅក្នុងឆ្នាំ ២០០៨):**

**១-** មជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក

**២-** មណ្ឌលសុខភាព :

| ខេត្ត-ក្រុង | ស្រុកប្រតិបត្តិ | | មណ្ឌលសុខភាព | ឧបត្ថម្ភគាំទ្រដោយ : |
|---|---|---|---|---|
| សៀមរាប | សៀមរាប | ២ | បន្ទាយស្រី | អង្គការ RACHA |
| | | ៣ | កន្ទ្រាំង | អង្គការ RACHA |
| | | ៤ | មណ្ឌល ១ | អង្គការ RACHA |
| | | ៥ | សៀមរាប | អង្គការ RACHA |
| | អង្គរជុំ | ៦ | ពួក | អង្គការ RACHA |
| | | ៧ | សសរស្តម | អង្គការ RACHA |
| | ក្រឡាញ់ | ៨ | កំពង់ថ្កូវ | អង្គការ RACHA |
| ពោធិសាត់ | សំពៅមាស | ៩ | កណ្ដៀង | អង្គការ RACHA |
| | | ១០ | ក្រគរ | អង្គការ RACHA |
| | | ១១ | ពាលញែក | អង្គការ RACHA |
| | | ១២ | ភ្នំក្រវាញ | អង្គការ RACHA |
| | បាកាន | ១៣ | បឹងខ្នារ | អង្គការ RACHA |
| កំពត | អង្គរជ័យ | ១៤ | តានី | អង្គការ RACHA |
| | កំពត | ១៥ | ក្រាំងអំពិល | អង្គការ RACHA |
| | ឈូក | ១៦ | ឈូក | អង្គការ RACHA |
| | កំពង់ត្រាច | ១៧ | កំពង់ត្រាច | អង្គការ RACHA |

**៣-** គ្លីនិកអង្គការមិនមែនរដ្ឋាភិបាល :

| **ខេត្ត-ក្រុង** | **ស្រុកប្រតិបត្តិ** | | **គ្លីនិកសុខភាព** | **ឧបត្ថម្ភគាំទ្រដោយ :** |
|---|---|---|---|---|
| ភ្នំពេញ | | ១៨ | ស្ទឹងមានជ័យ | អង្គការ RHAC |
| | | ១៩ | ចាក់អង្រែ | អង្គការ RHAC |
| | | ២០ | ទួលសង្កែ | អង្គការ RHAC |
| | | ២១ | ទឹកថ្លា | អង្គការ RHAC |
| | | ២២ | ទំនប់ថ្មី | អង្គការ RHAC |
| | | ២៣ | ផ្សារដេប៉ូ | អង្គការ RHAC |
| | | ២៤ | ទួលទំពូង | អង្គការ RHAC |
| ក្រុងព្រះសីហនុ | ក្រុងព្រះសីហនុ | ២៥ | ក្រុងព្រះសីហនុ | អង្គការ RHAC |
| បាត់ដំបង | បាត់ដំបង | ២៦ | បាត់ដំបង | អង្គការ RHAC |
| កំពង់ចាម | កំពង់ចាម | ២៧ | កំពង់ចាម | អង្គការ RHAC |
| | ជើងព្រៃ | ២៨ | ផ្អាវ | អង្គការ RHAC |
| | ត្បូងឃ្មុំ | ២៩ | សួង | អង្គការ RHAC |
| តាកែវ | ដូនកែវ | ៣០ | តាកែវ | អង្គការ RHAC |
| សៀមរាប | សៀមរាប | ៣១ | សៀមរាប | អង្គការ RHAC |
| | ក្រឡាញ់ | ៣២ | ពួក | អង្គការ RHAC |
| កំពង់ស្ពឺ | កំពង់ស្ពឺ | ៣៣ | កំពង់ស្ពឺ | អង្គការ RHAC |
| ស្វាយរៀង | ជីភូ | ៣៤ | បាវិត | អង្គការ RHAC |

**សេវាថែទាំសុខភាពដែលនឹងរៀបចំអោយដំណើរការធ្វើតេស្តឈាមរកមេរោគស្វាយ ( នៅក្នុងឆ្នាំ ២០០៩):**

**១-** មណ្ឌលសុខភាព :

| ខេត្ត-ក្រុង | ស្រុកប្រតិបត្តិ | | មណ្ឌលសុខភាព | ឧបត្ថម្ភគាំទ្រដោយ : |
|---|---|---|---|---|
| បន្ទាយមានជ័យ | ប៉ោយប៉ែត | ៣៥ | ប៉ោយប៉ែត | US-CDC |
| | មង្គលបូរី | ៣៦ | សេរីសោភ័ណ | US-CDC |
| បាត់ដំបង | បាត់ដំបង | ៣៧ | ស្វាយប៉ោ | US-CDC |
| | សំពៅលូន | ៣៨ | មន្ទីរពេទ្យបង្អែកសំពៅលូន | US-CDC |
| ព្រៃវែង | ព្រៃវែង | ៣៩ | HC Sub-satellites | CHAI (?) |
| | អ្នកលឿង | ៤០ | HC Sub-satellites | CHAI (?) |
| | ព្រះស្តេច | ៤១ | HC Sub-satellites | CHAI (?) |
| | កំពង់ត្របែក | ៤២ | HC Sub-satellites | CHAI (?) |
| | មេសាង | ៤៣ | HC Sub-satellites | CHAI (?) |
| តាកែវ | គីរីវង្ស | ៤៤ | HC Sub-satellites | EU/ITM |

**២-** គ្លីនិកអង្គការមិនមែនរដ្ឋាភិបាល :

| ខេត្ត-ក្រុង | ស្រុកប្រតិបត្តិ | | គ្លីនិកសុខភាព | ឧបត្ថម្ភគាំទ្រដោយ : |
|---|---|---|---|---|
| ភ្នំពេញ | | ៤៥ | ច្បារអំពៅ | Marie Stopes |
| កណ្តាល | តាខ្មៅ | ៤៦ | តាខ្មៅ | Marie Stopes |
| កោះកុង | ស្មាច់មានជ័យ | ៤៧ | កោះកុង | Marie Stopes |